# ឧបសម្ព័ន្ធ ១÷ កំណែប្រែតិចារិក ឯកសារ E1/131.1

Original FR: 00854989, p. 92, L. 3-11
Reviewed KH: 00853065, p. 65, L. 10-14



ឯកសារនេះ គឺជាកំណត់ហេតុនៃកិច្ចប្រជុំ ដែលមានសមាសភាពអ្នកចូលរួមដូចតទៅនេះ៖ សមមិត្តលេខា សមមិត្តអនុលេខា, សមមិត្ត ហែម, សមមិត្ត ខឿន, សមមិត្ត ស្រេង, សមមិត្ត ហង្ស សមមិត្ត សុត និងសមមិត្ត ទូច។ ដូច្នេះ យើងអាចសន្មតថា ទូត នេះហើយគឺជាឈ្មោះ កុយ ធួន នោះ។ របៀបវារៈ គឺពាក់ព័ន្ធទៅនឹងបញ្ហាបោះឆ្នោតថ្ងៃ២០ មីនា ៧៦ ក៏ដូចជាសភាពការណ៍នៅឧត្តរ ជាពិសេសនៅតំបន់១០៦ និង ១០៣។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ថា “កុយ ធួន ពិតជាត្រូវបានជាប់ -- ចាប់ខ្លួនមែន ក៏ដូចជាអ្នកចូលរួមនៅក្នុងកិច្ចប្រជុំនេះមួយចំនួនទៀត លើកលែងតែ ប៉ុល ពត, នួន ជា និង ខៀវ សំផន តែប៉ុណ្ណោះ”។ សមមិត្ត ហង្ស ទទួលបន្ទុកតំបន់១០៣ ក៏ត្រូវបានចាប់ខ្លួន សមមិត្ត សុត ហៅ តាផល ក៏ត្រូវបានចាប់ខ្លួន ហើយ កុយ ធួន ក៏ដូចគ្នា គឺត្រូវបានចាប់ខ្លួន។

[១៥:០៦:២៥]

ដូច្នេះ ខ្ញុំសូមបញ្ជាក់ថា ខៀវ សំផន បានចូលរួមនៅក្នុងកិច្ចប្រជុំមួយនេះ ហើយគេបានប្រាប់ឱ្យអ្នកទទួលខុសត្រូវរាយការណ៍ជាប្រចាំទៅដល់គណៈអចិន្ត្រៃយ៍អំពីស្ថានភាព ដែលបានកើតឡើងទោះជាពាក់ព័ន្ធទៅនឹងការសាងសង់ទំនប់សម្រាប់ស្រោចស្រព ឬក៏ពាក់ព័ន្ធទៅនឹងសភាពការណ៍ទូទៅនៅក្នុងតំបន់នីមួយៗ ហើយគេក៏បានស្នើឱ្យរាយការណ៍តាមទូរលេខផងដែរ ដើម្បីឱ្យគណៈអចិន្ត្រៃយ៍បានដឹងអំពីហេតុការណ៍ដែលបានកើតឡើង ហើយនិងអាចធ្វើសំណូមពរ ឬសេចក្ដីណែនាំទាន់ពេលវេលា។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំអស់សំណួរហើយលោកប្រធាន។ ហើយខ្ញុំសូមអរគុណសាក្សីដែលបានចូលរួមឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកចៅក្រម។ ម៉េចទៅលោក មាស វឿន មានបញ្ហាអីទេ?

**លោក មាស វឿន៖**

ខ្ញុំបាទ អត់មានបញ្ហាអីទេ។ ខ្ញុំអត់ដឹងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បើមិនមានបញ្ហាទេ អង្គជំនុំជម្រះនឹងបន្តការស្តាប់សក្ខីកម្មរបស់លោកតទៅទៀត។ ជាបន្តទៅនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីលោក មាស វឿន។